United Nations
Educational, Scientific and
Cultural Organization

**UNESCO Bangkok**
Asia and Pacific Regional Bureau
for Education







# ហេតុអ្វី




# បានជាភាសាមានសារៈសំខាន់ សម្រាប់គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍?



# ភាសា និងគោលដៅ អភិវឌ្ឍន៍សហស្សវត្សរ៍

យើងទទួលស្គាល់ថា វឌ្ឍនភាពឆ្ពោះទៅរកគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍មិនប្រព្រឹត្តទៅប្រកបដោយសមភាពនៅឡើយទេ។ សហគមន៍ក្រីក្រជាច្រើនដែលត្រូវការវឌ្ឍនភាពកំពុងរស់នៅក្នុងស្ថានភាពស្មុគស្មាញនៃភាសា។ ការជ្រើសរើសយកភាសាដ៏សមស្របបំផុតមួយក្នុងការប្រាស្រ័យទាក់ទងនឹងសហគមន៍ក្រីក្រទាំងនោះ គឺជាគន្លឹះដើម្បីសម្រេចឱ្យបាននូវគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ដែលនៅសេសសល់។ ក្នុងបរិបទដែលប្រកបដោយឧបសគ្គខ្លាំងបំផុតចំពោះគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍នោះ គឺនៅមានមនុស្សជាច្រើនដែលនៅមិនទាន់ចេះនិយាយភាសាជាតិ ឬភាសាអន្តរជាតិ។ ផ្ទុយមកវិញប្រសិនបើគេអភិវឌ្ឍដោយប្រើប្រាស់ភាសាទី១(ភាសាដើមកំណើត)របស់ពួកគេ នោះសហគមន៍នឹងអាចរកដំណោះស្រាយសមស្រប និងប្រកបដោយនិរន្តរភាព។ ឯកសារមួយនេះ នឹងពិពណ៌នាអំពីវិធីប្រើប្រាស់ភាសាទី១របស់សហគមន៍ ដើម្បីជ្រើសរើសរកដំណោះស្រាយសមស្របណាមួយក្នុងការឈានឆ្ពោះទៅរកវឌ្ឍនភាពជានិរន្ត នៃគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍នីមួយៗ។



## គោលដៅទី ១
## លុបបំបាត់ភាពក្រីក្រ និងការស្រេកឃ្លាន

**អត្តសញ្ញាណ** របស់មនុស្សកើតឡើងដោយសារ ភាសា វប្បធម៌ និងបរិស្ថាន ហើយការបាត់បង់ផ្នែកណាមួយនៃផ្នែកទាំង៣នេះវានឹងនាំឱ្យមានការខាតបង់យ៉ាងធំធេងសម្រាប់មនុស្សជាតិ និងសង្គម។ ឧទាហរណ៍: ភ្ជាប់ទៅនឹងគោលដៅទី៧នៃការអភិវឌ្ឍន៍សហស្សវត្សរ៍ សហគមន៍ជនជាតិភាគតិចជាច្រើនពឹងផ្អែកលើដំណាំតាមរដូវកាល ដែលធ្វើឱ្យពួកគាត់ងាយធ្លាក់ខ្លួនក្នុងភាពក្រីក្រ ដោយសារការខូចខាតផលដំណាំបណ្ដាលមកពីកាប្រែប្រួលអាកាសធាតុ។ កង្វះខាតព័ត៌មាន និងសេវាកម្មជាភាសាជនជាតិភាគតិចមានន័យថាសហគមន៍ជនជាតិភាគតិចត្រូវបានគេផាត់ចេញពីការអភិវឌ្ឍន៍ និងការអន្តរាគមន៍ជួយសង្គ្រោះ។ ការផ្ដល់ឱកាសដល់សហគមន៍ទាំងនេះ ដើម្បីឱ្យក្លាយជាបុគ្គលសំខាន់ក្នុងការអភិវឌ្ឍន៍ (ដោយប្រើប្រាស់ភាសាទី១ដែលពួកគេយល់បាន និងតាមមធ្យោបាយដែលសមស្របខាងវប្បធម៌) គឺជាការផ្ដល់អំណាចឱ្យពួកគេហ៊ានសម្រេចចិត្តលើអ្វីមួយ ដែលជះឥទ្ធិពលជាវិជ្ជមានដល់សុខុមាលភាពរបស់ពួកគេ។

## គោលដៅទី ២
## សម្រេចឱ្យបាននូវការអប់រំកម្រិតបឋមសិក្សាជាសកល

**កុមារជាច្រើន** ជួបប្រទះការលំបាកក្នុងការសិក្សារៀនសូត្រ នៅពេលដែលគ្រូបង្រៀនមិនបានប្រើភាសាទី១របស់ពួកគេ។ ភ័ស្តុតាងបានបង្ហាញយ៉ាងច្បាស់បង្ហាញយ៉ាងច្បាស់ថា ការសិក្សារៀនសូត្រ ដោយប្រើប្រាស់ភាសាទី១ជួយឱ្យសិស្សរៀនបានល្អជាងការប្រើប្រាស់ភាសាផ្សេង។ ការអប់រំពហុភាសាដោយផ្អែកលើភាសាដើមកំណើត ជួយជំរុញឱ្យមានការសិក្សាសមស្របនឹងបរិបទតាមរយៈភាសាទី១របស់កុមារ ខណៈពេលដែលឱ្យពួកគេឈោងចាប់យកភាសាជាតិ ឬភាសាអន្តរជាតិនៅឆ្នាំបន្តបន្ទាប់ទៀត។ នៅពេលដែលការសិក្សាប្រព្រឹត្តទៅជាភាសាទី១របស់កុមារក្នុងឆ្នាំដំបូងនៃការសិក្សា( និងបន្តទៅទៀតឱ្យបានយូរ តាមដែលអាចធ្វើទៅបាន )នោះគឺជាការជួយផ្ដល់អំណាចដល់ក្រុមគ្រួសារ និងសហគមន៍ទាំងមូល ឱ្យជួយគាំទ្រ និងលើកទឹកចិត្តកុមារក្នុងការបន្តរៀនសូត្រនៅក្រៅថ្នាក់រៀនបន្ថែមទៀត ព្រមទាំងរួមចំណែកជួយឱ្យកុមារនៅតែបន្តការសិក្សាបានវែងឆ្ងាយ និងរៀនសូត្របានច្រើន។



**គោលដៅទី ៣**
**លើកស្ទួយ**
**សមភាពយេនឌ័រ**
**និងផ្តល់**
**អំណាចដល់ស្ត្រី**

**ការជួយជំរុញផ្នែកអក្ខរកម្មដល់ស្ត្រី** និងការផ្តល់ព័ត៌មាន និងការគាំទ្រ ដោយប្រើប្រាស់ភាសាទី១ ជួយលើកស្ទួយស្ថានភាពសេដ្ឋកិច្ចរបស់ពួកគេ និងជះឥទ្ធិពលល្អដល់ក្រុមគ្រួសារក្នុងការចិញ្ចឹមបីបាច់ថែរក្សាកូន។ ឧទាហរណ៍ៈ ពេលស្ត្រីអានអត្ថបទស្តីពីការជួញដូរមនុស្ស អំពើហិង្សាក្នុងគ្រួសារ និងទម្រង់ផ្សេងៗនៃការព្យាបាលខុសឆ្គង ដែលសរសេរជាភាសាមួយដែលពួកគេយល់បានច្បាស់លាស់ នោះអំណាចត្រូវបានផ្តល់ដល់ពួកគេឱ្យធ្វើសកម្មភាពជាវិជ្ជមាន។ ដូចគ្នាដែរចំពោះវិស័យសុខាភិបាល និងសេដ្ឋកិច្ចឯករាជ្យ វាក៏ជួយផ្តល់ការយល់ដឹងជាវិជ្ជមានដោយផ្ទាល់ចំពោះសុខុមាលភាពគ្រួសារ។

**គោលដៅទី ៤ និង៥**
**កាត់បន្ថយអត្រា**
**មរណៈភាពរបស់កុមារ**
**និងលើកស្ទួយ**
**សុខុមាលភាពមាតា**

**សហគមន៍ជនជាតិភាគតិចជាច្រើន** ជួបប្រទះឧបសគ្គធំមួយ គឺភាសាដែលរារាំងពួកគេមិនឱ្យទទួលបានសេវាកម្មសុខភាព។ ការទទួលបានព័ត៌មានល្អៗអំពីអាហារូបត្ថម្ភ ការបំបៅកូនដោយទឹកដោះ ការផ្តល់ថ្នាំសង្កូវ និងរបៀបការពារ និងបង្ការជំងឺឆ្លងនានា អាចជួយសង្គ្រោះអាយុជីវិតរបស់ពួកគេបាន។ ស្ត្រីគឺជាអ្នកដែលអាចថែទាំសុខភាពខ្លួនឯង និងសមាជិកគ្រួសារបានល្អជាងគេ នៅពេលដែលពួកគេបានទទួលព័ត៌មានស្តីពីសុខភាពជាភាសាទី១ ដែលពួកគេអាចយល់បាន និងតាមរបៀបដែលសមស្របទៅនឹងបរិបទនៃវប្បធម៌របស់ពួកគេ។

**គោលដៅទី ៦**
**ប្រយុទ្ធប្រឆាំងនឹង**
**មេរោគអេដស៍/ជំងឺអេដស៍**
**គ្រុនចាញ់**
**និងជំងឺផ្សេងៗ**

**ការរើសអើង** ដែលទាក់ទងនឹងមេរោគអេដស៍/ជំងឺអេដស៍ ធ្វើឱ្យរបៀប ដែលយើងទំនាក់ទំនងអំពីបញ្ហានេះ កាន់តែមានសារៈសំខាន់ ព្រោះថានៅពេលដែលប្រជាជនមិនបានទទួលព័ត៌មានចាំបាច់ជាភាសាទី១ ដោយសមស្របនឹងវប្បធម៌ និងពីជនដែលពួកគេទុកចិត្ត នោះពួកគេនៅតែស្ថិតក្នុងស្ថានភាពងាយរងគ្រោះដោយសារមេរោគទាំងនោះដដែល។ ការផ្តល់ព័ត៌មានដោយប្រើប្រាស់ភាសាដែលពួកគេយល់ច្បាស់ ជួយបំពេញនូវចន្លោះខ្វះខាត រវាងការទទួលបានព័ត៌មាន និងការយល់ដឹងពីព័ត៌មាន ព្រមទាំងផ្តល់អំណាចឱ្យប្រជាជនសម្រេចចិត្តបានត្រឹមត្រូវដែលពន្យឺតការរីកសាយភាយ នៃជំងឺទាំងនោះផងដែរ។

---

[ឯកសារយោង] ព័ត៌មានខាងលើនេះផ្អែកលើឯកសារស្តីពីៈ *ហេតុអ្វីបានជាភាសាមានសារៈសំខាន់ចំពោះគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍* (យូនេស្កូ បាងកក ២០១២) (ដកស្រង់ពីៈ *http://unesdoc.unesco.org/images/0021/00215 2/215296E.pdf*) និង *ហេតុអ្វីបានជាភាសាមានសារៈសំខាន់ៈ ការសម្រេចគោលដៅអភិវឌ្ឍសហស្សវត្សរ៍ឱ្យបានដោយប្រើប្រាស់ភាសាក្នុងតំបន់* (អេសអាយអិល អន្តរជាតិ ២០០៨)



## គោលដៅទី ៧ ធានាការអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាព

តំបន់ជាច្រើនក្នុងពិភពលោក ដែលសម្បូរធនធានធម្មជាតិ និងជីវចម្រុះ ក៏ជាកន្លែងដែលមានវប្បធម៌ត្រចះត្រចង់ និងភាសាសម្បូរបែបផងដែរ។ ការអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាពត្រូវពឹងផ្អែកលើការចូលរួមពីក្រុមជនជាតិភាគតិចដែលយកប្រព័ន្ធអេកូឡូស៊ីជាទីពំនាក់អាស្រ័យដើម្បីរស់នៅ និងសម្រាប់អនាគតរបស់ពួកគេ។ ការផ្តួចផ្តើមអភិវឌ្ឍន៍ទាំងឡាយណា ដែលមិនប្រើប្រាស់ភាសាទី១របស់ប្រជាជនទាំងនេះ ជាការរឹតត្បិតការចូលរួមរបស់ជនជាតិភាគតិចដែលនិយាយភាសាបន្ទាប់បន្សំជាភាសាកំណើត ហើយដែលនាំឱ្យបាត់បង់ចំណេះដឹង និងបទពិសោធន៍ជាក់លាក់ណាមួយក្នុងតំបន់នោះ។

## គោលដៅទី ៨ បង្កើតភាពជាដៃគូជាសកលក្នុងកិច្ចការអភិវឌ្ឍន៍

ការបង្កើតភាពជាដៃគូជាសកលត្រូវការការទំនាក់ទំនងច្បាស់លាស់។ ការបង្ខិតបង្ខំប្រជាជនឱ្យទំនាក់ទំនងដោយប្រើប្រាស់ភាសាដែលពួកគេមិនយល់ច្បាស់លាស់ គឺជាការដាក់កំហិតដល់សមត្ថភាពនៃការចូលរួមក្នុងបណ្តាញនានា។ បច្ចេកវិទ្យាព័ត៌មាន និងការទំនាក់ទំនង(ICT) ដែលប្រើប្រាស់ភាសាទី១ របស់ប្រជា-ជនអនុញ្ញាតឱ្យមានការចូលរួម និងជួយបង្កើនល្បឿនអភិវឌ្ឍន៍លើគ្រប់គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ ដែលសម្រួលដល់ការចែករំលែកចំណេះដឹង និងព័ត៌មាន បើមិនដូច្នោះទេពួក-គេមិនអាចប្រើប្រាស់ចំណេះដឹង និងព័ត៌មានដើម្បីផ្តល់ជាវិធីសាស្រ្ត ក្នុងការលើកស្ទួយភាពជាដៃគូរវាងវិស័យនានាបានឡើយ។



LEAD
Communities Moving Forward

United Nations
Educational, Scientific and
Cultural Organization

**UNESCO Bangkok**
Asia and Pacific Regional Bureau
for Education

# អិលអ៊ីអេឌី អាស៊ី

ការដោះស្រាយបញ្ហាជុំវិញភាសា និងវប្បធម៌អាចជាឧបសគ្គមួយ និងទាមទារជំនាញឯកទេស និងបទពិសោធន៍ជាក់លាក់។ **អិលអ៊ីអេឌី**-អាស៊ី ប្តេជ្ញាជួយសម្រេចឱ្យបាននូវគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍សម្រាប់មនុស្សទាំងអស់មិនថាពួកគេនិយាយភាសាអ្វីឡើយ ហើយក៏មានឆន្ទៈជួយដល់ប្រជាជន ឬក្រុមមនុស្សដែលព្យាយាមពិចារណាលើបញ្ហាជុំវិញភាសា និងវប្បធម៌។ សម្រាប់ព័ត៌មានបន្ថែមអំពីរបៀបលើកស្ទួយគុណសម្បត្តិនៃការប្រើប្រាស់ភាសាទី១ ក្នុងការងារអភិវឌ្ឍន៍ សូមទាក់ទង អិលអ៊ីអេឌី តាមរយៈសារអេឡិចត្រូនិក៖ languageimpact@sil.org ។

**អិលអ៊ីអេឌី**-អាស៊ី ជាអង្គភាពមួយរបស់ **អេសអាយអិល**-អន្តរជាតិ។ **អេសអាយអិល** គឺជាអង្គការមិនរកប្រាក់ចំណេញ ដែលជាអ្នកផ្តល់ការប្រឹក្សាយោបល់ពិសេសដល់ក្រុមប្រឹក្សាសង្គម និងសេដ្ឋកិច្ចនៃអង្គការសហប្រជាជាតិ ( ECOSOC ) ហើយក៏ជាអង្គការដៃគូផ្លូវការមួយរបស់អង្គការយូនេស្កូក្នុងឋានៈជាទីប្រឹក្សាយោបល់។

# ក្រុមការងារអប់រំពហុភាសាប្រចាំទ្វីបអាស៊ី ( MLE WG )

ក្រុមការងារអប់រំពហុភាសាប្រចាំទ្វីបអាស៊ីរួមមាន៖ភ្នាក់ងារដៃគូអង្គការសហប្រជាជាតិអង្គការអន្តរជាតិដែលពាក់ព័ន្ធអង្គការសង្គមស៊ីវិល និងគ្រឹះស្ថានអប់រំនានា ដែលត្រូវបានបង្កើតឡើងនៅឆ្នាំ២០០៤ ស្ថិតនៅក្រោមក្រុមការងារថ្នាក់តំបន់ស្តីពីប្រធានបទ ( ការអប់រំសម្រាប់ទាំងអស់គ្នា ) ដើម្បីដកចេញនូវរនាំងបាំងចំពោះការទទួលបានការអប់រំមួយប្រកបដោយគុណភាពសម្រាប់សហគមន៍ជនជាតិភាគតិចតាមរយៈការសម្របសម្រួលបច្ចេកទេស និងការជួយគាំទ្រជាពិសេសចំពោះគំនិតផ្តួចផ្តើមនៃការអប់រំពហុភាសា និងការតស៊ូមតិលើគោលនយោបាយដែលទាក់ទងនៅក្នុង

តំបន់អាស៊ីប៉ាស៊ីហ្វិកទាំងមូល។

សម្រាប់ព័ត៌មានបន្ថែម សូមចូលទៅកាន់គេហទំព័ររបស់ក្រុមការងារអប់រំពហុភាសាប្រចាំទ្វីប អាស៊ី៖

www.asiapacificmle.net។



APL/13/005-1000

Photo © Warren Field

TH/APL/13/005-1000